ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន
លេខ: ០៧០ សរណន.សក

# សារាចរណែនាំ
# ស្តីពី
# ផែនការកម្ម ការសាងសង់ និងប្រតិបត្តិការកំពង់ផែ
# នៅក្នុងព្រះរាជាណាចក្រកម្ពុជា

យោងអនុក្រឹត្យលេខ ១៤អនក្រ.បក ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងដើម្បីធានាការគ្រប់គ្រង និងការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព លក្ខណៈបច្ចេកទេសត្រឹមត្រូវ សុវត្ថិភាព និងសន្តិសុខ ក្នុងការអភិវឌ្ឍកំពង់ផែ រួមចំណែកការពារបរិស្ថានឲ្យបានល្អ ព្រមទាំងជួយជំរុញឲ្យមានការវិនិយោគលើការងារកសាងអភិវឌ្ឍន៍កំពង់ផែនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងសាធារណការ និងដឹកជញ្ជូន សូមធ្វើការណែនាំ ដូចតទៅ៖

## ក. ការកសាងកំពង់ផែ

១. ការកសាងកំពង់ផែ ឬ ការបង្កើតកំពង់ផែ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវសមស្របតាមលក្ខណៈវិនិច្ឆ័យសម្រាប់ផែនការកម្មកំពង់ផែ ដូចខាងក្រោម៖

**ទីតាំង និងការកសាងកំពង់ផែ**

- កំពង់ផែ ត្រូវស្ថិតនៅក្នុងគម្លាតសមស្រប និងក្នុងតំបន់ប្រើប្រាស់ដី ដែលច្បាប់បានកំណត់ ដោយមានលក្ខខណ្ឌធម្មជាតិសមស្រប
- កំពង់ផែ ត្រូវកសាងឡើងនៅកន្លែង ដែលគេអាចចាត់វិធានការសុវត្ថិភាព សន្តិសុខ និង កិច្ចការពារបរិស្ថានបាន។

**គោលបំណងនៃការប្រើប្រាស់**

- កំពង់ផែ ដែលបានស្នើឡើងដើម្បីសាងសង់ ត្រូវដាក់ប្រើប្រាស់សម្រាប់ទំនិញ អ្នកដំណើរ ឬសម្រាប់គោលបំណងពិសេសណាមួយជាក់លាក់។

**សមត្ថភាពកំពង់ផែ**

- បរិមាណទំនិញឆ្លងកាត់ ចំនួនអ្នកដំណើរចុះឡើង និងសមត្ថភាពផ្សេងៗទៀតរបស់កំពង់ផែ ត្រូវកំណត់ឲ្យបានច្បាស់ត្រឹមត្រូវ ឆ្លើយតបតាមលក្ខខណ្ឌធម្មជាតិ គម្លាតកំពង់ផែ សេចក្តីត្រូវការ និងការផ្គត់ផ្គង់ទំនិញ និង/ឬអ្នកដំណើរ ព្រមទាំងលក្ខណៈហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធ។

ទំហំ និងគម្រោងប្លង់បរិក្ខារនាវាចរណ៍ កណ្តាលផែ

- ត្រូវគូសទំហំ និងគម្រោងប្លង់បរិក្ខារនាវាចរណ៍ កណ្តាលផែឲ្យបានច្បាស់លាស់
- បរិក្ខារនាវាចរណ៍ កណ្តាលផែ ដែលចាំបាច់ទាំងឡាយ នៅក្នុងកំពង់ផែ ត្រូវកសាងឡើង និង ដាក់ប្រើប្រាស់សម្រាប់នាវា ទំនិញ និងអ្នកដំណើរតាមរបៀបមួយ ដែលមានសុវត្ថិភាព សន្តិសុខ និង បរិស្ថានល្អ។

គោលនយោបាយកំពង់ផែ

- ការកសាងកំពង់ផែ ត្រូវធ្វើឡើងឲ្យសមស្របនឹងគោលនយោបាយជាតិស្តីពីកំពង់ផែ ផែនការមេជាតិស្តីពីកំពង់ផែ ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិអន្តរជាតិ ដែលពាក់ព័ន្ធនឹងកំពង់ផែ។

២. រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងកសាងកំពង់ផែ ឬបង្កើតកំពង់ផែ ត្រូវដាក់ពាក្យសុំពិនិត្យ និងវាយតម្លៃផែនការកម្មកំពង់ផែមកក្រសួងសាធារណការ និងដឹកជញ្ជូន តាមគំរូដូចមានភ្ជាប់នៅក្នុងសារាចរណែនាំនេះ។

ក្នុងការដាក់ពាក្យសុំ រូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវភ្ជាប់នូវឯកសារដូចខាងក្រោម៖

- លិខិតចុះបញ្ជីពាណិជ្ជកម្ម
- លក្ខន្តិកៈក្រុមហ៊ុន
- ប្លង់កំពង់ផែ
- គោលការណ៍បង្កើតកំពង់ផែ
- ប្លង់កម្មសិទ្ធិដីធ្លី
- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- ឯកសារពាក់ព័ន្ធដទៃទៀត បើចាំបាច់។

៣. ក្នុងការពិនិត្យពាក្យសុំពិនិត្យ និងវាយតម្លៃផែនការកម្មកំពង់ផែ មន្ត្រីមានសមត្ថកិច្ចនៃក្រសួងសាធារណការ និងដឹកជញ្ជូន មានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យផ្ទៀងផ្ទាត់ពាក្យសុំពិនិត្យ និងវាយតម្លៃផែនការកម្មកំពង់ផែ រួមទាំងឯកសារពាក់ព័ន្ធ
- ចុះសិក្សា ពិនិត្យ និងវាយតម្លៃអំពីគម្រោងអភិវឌ្ឍន៍កំពង់ផែដល់ទីកន្លែង។

៤. ក្រោយបានបំពេញចប់សព្វគ្រប់ត្រឹមត្រូវ ស្របតាមចំណុចក.២ និងក.៣ ខាងលើ ក្រសួងសាធារណការ និងដឹកជញ្ជូន អាចចេញលិខិតវាយតម្លៃផែនការកម្មកំពង់ផែឲ្យទៅរូបវន្តបុគ្គល ឬនីតិបុគ្គលពាក់ព័ន្ធ ស្របតាមគំរូដូចមានភ្ជាប់នៅក្នុងសារាចរណែនាំនេះ។

៥. ក្រសួងសាធារណការ និងដឹកជញ្ជូន មានសិទ្ធិបដិសេធចំពោះការកសាងកំពង់ផែ ក្នុងករណីដូចខាងក្រោម៖

- គម្រោងកសាងកំពង់ផែ មិនស្របតាមលក្ខណៈវិនិច្ឆ័យសម្រាប់ផែនការកម្មកំពង់ផែ
- រូបវន្តបុគ្គល ឬនីតិបុគ្គល បដិសេធមិនអនុញ្ញាតឲ្យមន្ត្រីមានសមត្ថកិច្ចនៃក្រសួងសាធារណការ និងដឹកជញ្ជូន ចុះសិក្សា ពិនិត្យ និងវាយតម្លៃផែនការកម្មកំពង់ផែដល់ទីកន្លែង ឬខកខានមិនបានផ្តល់ព័ត៌មាន ឬបំពេញចំណុចខ្វះខាតណាមួយ តាមការស្នើសុំរបស់មន្ត្រីមានសមត្ថកិច្ច។/

## ខ. ការសាងសង់កំពង់ផែ

១. ការសាងសង់កំពង់ផែ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវសមស្របតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការសាងសង់កំពង់ផែ ដូចខាងក្រោម៖

**ផែនការការងារ**

- ត្រូវកំណត់អំពីផែនការការងារ ដែលមានគម្រោងការងារ និង គម្រោងពេលវេលាឲ្យបានច្បាស់លាស់
- ត្រូវកំណត់អំពីទុនវិនិយោគ រួមទាំងប្រភពហិរញ្ញវត្ថុឲ្យបានច្បាស់លាស់។

**ប្លង់កសាងហេដ្ឋារចនាសម្ព័ន្ធ**

- ត្រូវមានប្លង់ស្ថាបត្យកម្មបបនីយកណ្ឋផែត្រឹមត្រូវ
- ត្រូវមានប្លង់វិស្វកម្មបបនីយកណ្ឋផែត្រឹមត្រូវ ដោយមានប្លង់លំអិត ឬប្លង់បង្គុំផង ក្រោយពីបានការយល់ព្រមលើប្លង់ស្ថាបត្យកម្មបបនីយកណ្ឋផែរួច។

**កិច្ចការពារបរិស្ថាន**

- ត្រូវមានវិធានការការពារបរិស្ថាន រួមទាំងកម្មវិធីត្រួតពិនិត្យតាមដានបរិស្ថាន និងត្រូវយកទៅអនុវត្តនៅក្នុងអំឡុងពេលការងារសាងសង់បបនីយកណ្ឋផែ។

**សន្តិសុខ និងសុវត្ថិភាព**

- ត្រូវមានវិធានការសន្តិសុខ និងសុវត្ថិភាព និងត្រូវយកទៅអនុវត្ត នៅក្នុងអំឡុងពេលការងារសាងសង់បបនីយកណ្ឋផែ។

២. រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងសាងសង់កំពង់ផែ ត្រូវដាក់ពាក្យសុំមកក្រសួងសាធារណការ និងដឹកជញ្ជូន ស្របតាមគំរូដូចមានភ្ជាប់នៅក្នុងសាពចរណែនាំនេះ។

ក្នុងការដាក់ពាក្យសុំ រូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវភ្ជាប់នូវឯកសារដូចខាងក្រោម៖

- ប្លង់ស្ថាបត្យកម្មសំណង់កំពង់ផែ
- ប្លង់វិស្វកម្មសំណង់កំពង់ផែ ឬ ប្លង់បង្គុំសំណង់កំពង់ផែ
- ផែនការការងារសម្រាប់ការសាងសង់កំពង់ផែ។

៣. មន្ត្រីមានសមត្ថកិច្ចនៃក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវពិនិត្យ និងផ្តល់ការយល់ព្រមលើប្លង់ស្ថាបត្យកម្មសំណង់កំពង់ផែ និងប្លង់វិស្វកម្មសំណង់កំពង់ផែ។

៤. ក្រោយបានបញ្ចប់សព្វគ្រប់ត្រឹមត្រូវ ស្របតាមចំណុចខ.២ និងខ.៣ ខាងលើ ក្រសួងសាធារណការ និងដឹកជញ្ជូនអាចចេញលិខិតអនុញ្ញាតសាងសង់កំពង់ផែ តាមគំរូដូចមានភ្ជាប់នៅក្នុងសាពចរណែនាំនេះ។

៥. រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានបំពេញចប់សព្វគ្រប់នូវការងារសាងសង់កំពង់ផែ ដោយផ្នែកណាមួយ ឬទាំងមូល ត្រូវផ្ញើរបាយការណ៍បញ្ចប់ការងារសាងសង់កំពង់ផែនោះ មកក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីត្រួតពិនិត្យ និងវាយតម្លៃការងារសាងសង់កំពង់ផែ និងពិនិត្យផ្ទៀងផ្ទាត់របាយការណ៍បញ្ចប់ការងារសាងសង់កំពង់ផែ ដោយផ្នែកណាមួយ ឬទាំងមូល ដើម្បីដាក់ឲ្យធ្វើប្រតិបត្តិការ។

## គ. ប្រតិបត្តិការកំពង់ផែ

១. ប្រតិបត្តិការកំពង់ផែ ត្រូវសមស្របតាមលក្ខណៈវិនិច្ឆ័យសម្រាប់ប្រតិបត្តិការកំពង់ផែ ដូចខាងក្រោម៖

លក្ខណៈកំពង់ផែ

- កំពង់ផែ ទោះបីជាមួយផ្នែក ឬទាំងមូល ត្រូវមានលទ្ធភាពបំពេញមុខងារពេញលេញ
- កំពង់ផែ ត្រូវមានប្រព័ន្ធ ដើម្បីកត់ត្រាទុកនូវបរិមាណទំនិញឆ្លងកាត់ ចំនួនអ្នកដំណើរ ចំនួននាវាចូល និង ព័ត៌មានចាំបាច់ផ្សេងទៀត។

ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ

ការប្រើប្រាស់ឋបនីយកណ្ឌផែ

- ការប្រើប្រាស់ឋបនីយកណ្ឌផែ និងឧបករណ៍ ត្រូវសមស្របតាមគោលបំណងនៃការកសាងកំពង់ផែ។

ការថែទាំ និងការគ្រប់គ្រងឋបនីយកណ្ឌផែ

- ត្រូវរៀបចំផែនការដែលអាចអនុវត្តបាន សម្រាប់ការថែទាំ និងការគ្រប់គ្រងឋបនីយកណ្ឌផែ។

បរិស្ថាន សុវត្ថិភាព និងសន្តិសុខ

- ត្រូវរៀបចំវិធានការសម្រាប់កិច្ចការពារបរិស្ថាន សុវត្ថិភាព និងសន្តិសុខ នៅកំពង់ផែ។

ផែនការគ្រោះអាសន្ន

- ត្រូវរៀបចំផែនការគ្រោះអាសន្ន ដែលឆ្លើយតបទៅនឹងគ្រោះថ្នាក់ ការកំពប់ប្រេង ឬគ្រោះថ្នាក់ធម្មជាតិ និងទម្រង់គ្រោះថ្នាក់ប្រហាក់ប្រហែលផ្សេងទៀត នៅតំបន់ទឹក និងគោករបស់កំពង់ផែ។

២. រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានបញ្ចប់ការងារសាងសង់កំពង់ផែ ត្រូវដាក់ពាក្យសុំធ្វើប្រតិបត្តិការកំពង់ផែមកក្រសួងសាធារណការ និងដឹកជញ្ជូន តាមគំរូដូចមានភ្ជាប់នៅក្នុងសារាចរណែនាំនេះ។

ក្នុងការដាក់ពាក្យសុំ រូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវភ្ជាប់មកនូវឯកសារដូចខាងក្រោម៖

- របាយការណ៍បញ្ចប់ការងារសាងសង់
- ផែនការប្រតិបត្តិការឋបនីយកណ្ឌផែ និងឧបករណ៍
- ផែនការថែទាំ និងគ្រប់គ្រងឋបនីយកណ្ឌផែ
- វិធានការបរិស្ថាន រួមទាំងកម្មវិធីត្រួតពិនិត្យតាមដានបរិស្ថាន បើចាំបាច់
- ផែនការសន្តិសុខឋបនីយកណ្ឌផែ បើចាំបាច់។

៣. ក្រោយបានបំពេញចប់សព្វគ្រប់ត្រឹមត្រូវ ស្របតាមចំណុចគ.១ និងគ.២ ខាងលើ ក្រសួងសាធារណការ និងដឹកជញ្ជូន អាចចេញលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែឲ្យរូបវន្តបុគ្គល ឬនីតិបុគ្គលពាក់ព័ន្ធ ស្របតាមគំរូដូចមានភ្ជាប់នៅក្នុងសារាចរណែនាំនេះ។

## ឃ. សមត្ថកិច្ចទទួលខុសត្រូវ

១. មន្ត្រីមានសមត្ថកិច្ចនៃក្រសួងសាធារណការ និងដឹកជញ្ជូននៅថ្នាក់ក្រសួង មានសិទ្ធិអនុវត្តកិច្ចការសម្រាប់ផែនការកម្ម ការសាងសង់ និងប្រតិបត្តិការកំពង់ផែ សម្រាប់កំពង់ផែថ្នាក់ទី១ និងទី២។

២. មន្ត្រីមានសមត្ថកិច្ចនៃក្រសួងសាធារណការ និងដឹកជញ្ជូននៅថ្នាក់រាជធានី ខេត្ត មានសិទ្ធិអនុវត្តកិច្ចការសម្រាប់ផែនការកម្ម ការសាងសង់ និងប្រតិបត្តិការកំពង់ផែ សម្រាប់កំពង់ផែថ្នាក់ទី៣។

៣. មន្ត្រីមានសមត្ថកិច្ចនៃក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវរៀបចំបញ្ជីពិនិត្យផ្ទៀងផ្ទាត់សម្រាប់ផែនការកម្មកំពង់ផែ ការសាងសង់កំពង់ផែ និងប្រតិបត្តិការកំពង់ផែ ដើម្បីជាជំនួយដល់ដំណើរត្រួតពិនិត្យ និងវាយតម្លៃ ស្របតាមលក្ខណៈវិនិច្ឆ័យ ដូចមានកំណត់នៅក្នុងចំណុចក.១ ចំណុចខ.១ និងចំណុចគ.១ ខាងលើ។ បញ្ជីពិនិត្យផ្ទៀងផ្ទាត់នេះ ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

ទទួលបានសារាចរណែនាំនេះ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានសាធារណការ អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូន អគ្គាធិការនៃអគ្គាធិការដ្ឋាន លោកប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត លោកប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង និងអ្នកពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តសារាចរណែនាំនេះ តាមភារកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ២០១១

**រដ្ឋមន្ត្រី**

ត្រាំ អ៊ីវតឹក

**ចម្លងជូនៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងពាណិជ្ជកម្ម
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- សាលារាជធានី ខេត្ត
  "ដើម្បីជូនជ្រាប"
- គ្រប់អង្គភាពក្រោមឱវាទក្រសួង
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

គំរូពាក្យសុំពិនិត្យ និងវាយតម្លៃផែនការកម្មកំពង់ផែ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យសុំពិនិត្យ និងវាយតម្លៃផែនការកម្មកំពង់ផែ

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ............................ ភេទ.............. ថ្ងៃខែឆ្នាំកំណើត .......................... សញ្ជាតិ..................ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ......... ផ្លូវលេខ........ក្រុមទី.........ភូមិ................... ឃុំ-សង្កាត់........................ស្រុក-ខណ្ឌ-ក្រុង.........................រាជធានី-ខេត្ត................................ អត្តសញ្ញាណប័ណ្ណលេខ................. ឬ ប័ណ្ណគ្រួសារលេខ..................... ឬ លិខិតឆ្លងដែនលេខ ................មុខរបរជា......................................................។

**សូមគោរពជូន**

**ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន**

**កម្មវត្ថុ:** សំណើសុំពិនិត្យ និងវាយតម្លៃផែនការកម្មកំពង់ផែ..................................................។

យោងតាមកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំ សូមគោរពស្នើសុំ **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងវាយតម្លៃផែនការកម្មកំពង់ផែរបស់ខ្ញុំបាទ-នាងខ្ញុំដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី.........ខែ............ឆ្នាំ..............

**ហត្ថលេខា**

ជូនភ្ជាប់មកជាមួយៈ

- អត្តសញ្ញាណប័ណ្ណ ឬ ប័ណ្ណគ្រួសារ ឬ លិខិតឆ្លងដែន
- លិខិតចុះបញ្ជីពាណិជ្ជកម្ម
- លក្ខន្តិកៈក្រុមហ៊ុន
- ប្លង់កំពង់ផែ
- ប្លង់កម្មសិទ្ធិដីធ្លី
- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- គោលការណ៍បង្កើតកំពង់ផែ
- ឯកសារពាក់ព័ន្ធដែលចាំបាច់។

គំរូលិខិតវាយតម្លៃផែនការកម្មកំពង់ផែ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

លេខ៖ ...............................សក/ផក

រាជធានីភ្នំពេញ ថ្ងៃទី ...... ខែ ........... ឆ្នាំ ..........

# លិខិតវាយតម្លៃផែនការកម្មកំពង់ផែ

រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន សូមបញ្ជាក់ថា ៖

១. នាមករណ៍ក្រុមហ៊ុន ៖.......................................................................................

២. លេខចុះបញ្ជីពាណិជ្ជកម្ម ៖.......................................................................................

៣. ប្រធានក្រុមហ៊ុន ៖ .....................................................................................

៤. ទីស្នាក់ការក្រុមហ៊ុន ៖ .....................................................................................

.......................................................................................

.......................................................................................

.......................................................................................

៥. កម្មវត្ថុ ៖ .....................................................................................

បានបំពេញលក្ខខណ្ឌត្រឹមត្រូវ សម្រាប់ការកសាងកំពង់ផែ ស្របតាមលក្ខណៈវិនិច្ឆ័យសម្រាប់ផែនការកម្មកំពង់ផែ។

**រដ្ឋមន្ត្រី**

គំរូពាក្យសុំសាងសង់កំពង់ផែ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំសាងសង់កំពង់ផែ

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ............................ ភេទ.............. ថ្ងៃខែឆ្នាំកំណើត .......................... សញ្ជាតិ..................ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ......... ផ្លូវលេខ........ក្រុមទី.........ភូមិ.................. ឃុំ-សង្កាត់........................ស្រុក-ខណ្ឌ-ក្រុង........................រាជធានី-ខេត្ត................................ អត្តសញ្ញាណប័ណ្ណលេខ................. ឬ ប័ណ្ណគ្រួសារលេខ...................... ឬ លិខិតឆ្លងដែនលេខ ................មុខរបរជា.......................................................។

## សូមគោរពជូន
## ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

**កម្មវត្ថុ:** សំណើសុំសាងសង់កំពង់ផែ..........................................................។

ដោយខ្ញុំបាទ-នាងខ្ញុំ បានទទួលលិខិតវាយតម្លៃផែនការកម្មកំពង់ផែលេខ.........ចុះថ្ងៃទី....ខែ..... ឆ្នាំ.........របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ខ្ញុំបាទ-នាងខ្ញុំ សូមគោរពស្នើសុំ **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាអនុញ្ញាតឲ្យខ្ញុំបាទ-នាងខ្ញុំសាងសង់កំពង់ផែដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី...........ខែ............ឆ្នាំ...................

**ហត្ថលេខា**

ជូនភ្ជាប់មកជាមួយៈ

- អត្តសញ្ញាណប័ណ្ណ ឬ ប័ណ្ណគ្រួសារ ឬ លិខិតឆ្លងដែន
- ប្លង់ស្ថាបត្យកម្មសាងសង់កំពង់ផែ
- ប្លង់វិស្វកម្មសាងសង់កំពង់ផែ ឬប្លង់បង្គុំសំណង់កំពង់ផែ
- ផែនការការងារសម្រាប់សាងសង់

គំរូលិខិតអនុញ្ញាតសាងសង់កំពង់ផែ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

លេខ៖ .................................សក/សក

រាជធានីភ្នំពេញ ថ្ងៃទី ...... ខែ .......... ឆ្នាំ ............

# លិខិតអនុញ្ញាតសាងសង់កំពង់ផែ

រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន សូមបញ្ជាក់ថា ៖

១. នាមករណ៍ក្រុមហ៊ុន ៖..........................................................................................

២. លេខចុះបញ្ជីពាណិជ្ជកម្ម ៖..........................................................................................

៣. ប្រធានក្រុមហ៊ុន ៖ ..........................................................................................

៤. ទីស្នាក់ការក្រុមហ៊ុន ៖ ..........................................................................................

..........................................................................................

..........................................................................................

៥. កម្មវត្ថុ ៖ ..........................................................................................

..........................................................................................

បានបំពេញលក្ខខណ្ឌត្រឹមត្រូវ សម្រាប់ការសាងសង់កំពង់ផែ ស្របតាមលក្ខណៈវិនិច្ឆ័យសាងសង់កំពង់ផែ។

**រដ្ឋមន្ត្រី**

គំរូពាក្យសុំធ្វើប្រតិបត្តិការកំពង់ផែ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំធ្វើប្រតិបត្តិការកំពង់ផែ

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ............................ ភេទ.............. ថ្ងៃខែឆ្នាំកំណើត .......................... សញ្ជាតិ..................ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ......... ផ្លូវលេខ........ក្រុមទី.........ភូមិ.................. ឃុំ-សង្កាត់........................ស្រុក-ខណ្ឌ-ក្រុង..........................រាជធានី-ខេត្ត................................ អត្តសញ្ញាណប័ណ្ណលេខ................ ឬ ប័ណ្ណគ្រួសារលេខ..................... ឬ លិខិតឆ្លងដែនលេខ ................មុខរបរជា......................................................។

## សូមគោរពជូន
## ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

**កម្មវត្ថុ:** សំណើសុំធ្វើប្រតិបត្តិការកំពង់ផែ.............................................................។

ដោយខ្ញុំបាទ-នាងខ្ញុំ បានទទួលលិខិតអនុញ្ញាតសាងសង់កំពង់ផែលេខ............ ចុះថ្ងៃទី......... ខែ......ឆ្នាំ................ខ្ញុំបាទ-នាងខ្ញុំ សូមគោរពស្នើសុំ **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាអនុញ្ញាតឲ្យខ្ញុំបាទ-នាងខ្ញុំធ្វើប្រតិបត្តិការកំពង់ផែដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី...........ខែ...........ឆ្នាំ...............

ជូនភ្ជាប់មកជាមួយៈ

**ហត្ថលេខា**

- របាយការណ៍បញ្ចប់ការងារសាងសង់កំពង់ផែ
- ផែនការប្រតិបត្តិការបរិបនីយកណ្តាផែ
- ផែនការថែទាំង និងគ្រប់គ្រងបរិបនីយកណ្តាផែ
- ផែនការការពារបរិស្ថាន បើចាំបាច់
- ផែនការបរិបនីយកណ្តាផែ បើចាំបាច់
- ឯកសារផ្សេងទៀត

គំរូលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

លេខ៖ ..................................សក/បត

រាជធានីភ្នំពេញ ថ្ងៃទី ...... ខែ .......... ឆ្នាំ ............

## លិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ

រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន សូមបញ្ជាក់ថា ៖

១. នាមករណ៍ក្រុមហ៊ុន ៖...........................................................................................

២. លេខចុះបញ្ជីពាណិជ្ជកម្ម ៖...........................................................................................

៣. ប្រធានក្រុមហ៊ុន ៖ ...........................................................................................

៤. ទីស្នាក់ការក្រុមហ៊ុន ៖ ...........................................................................................

...........................................................................................

...........................................................................................

៥. កម្មវត្ថុ ៖ ...........................................................................................

...........................................................................................

បានបំពេញលក្ខខណ្ឌត្រឹមត្រូវ សម្រាប់ធ្វើប្រតិបត្តិការកំពង់ផែ ស្របតាមលក្ខណៈវិនិច្ឆ័យសម្រាប់ប្រតិបត្តិការកំពង់ផែ។

**រដ្ឋមន្ត្រី**